**សលាកប័ត្រព័ត៌មាន៖** កម្រងករណីសិក្សា៖ សិទ្ធិមនុស្សទំនងជាបញ្ហាបន្ទាប់បន្សំពីការអភិវឌ្ឍសេដ្ឋកិច្ចក្នុងរាជធានីភ្នំពេញ
**កាលប្បវត្តិ៖** ដើមឆ្នាំ២០០០ រហូតមកដល់បច្ចុប្បន្ន
**ទិដ្ឋភាពរួម៖** វិនិយោគទុនបរទេសដែលបានកើនឡើងនៅរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះបាននាំមកនូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់នៅព្រះរាជាណាចក្រកម្ពុជា("កម្ពុជា")។ ប៉ុន្តែ ការរីកចម្រើនសេដ្ឋកិច្ចនេះក៏បានប៉ះពាល់ដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋសាមញ្ញផងដែរ ។ បើទោះជាមានការតវ៉ានិងយុទ្ធនាការជាច្រើនរបស់សង្គមស៊ីវិល ក៏សិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញទំនងត្រូវបានចាត់ទុកជាបញ្ហាបន្ទាប់បន្សំជាងការអភិវឌ្ឍសេដ្ឋកិច្ច ហេតុដូច្នេះរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ត្រូវតែដោះស្រាយចំពោះអតុល្យភាពនេះដើម្បីធានាថាការអភិវឌ្ឍបានផ្តល់ផលប្រយោជន៍ដល់មនុស្សគ្រប់គ្នា។

## សេចក្តីផ្តើម

ចាប់តាំងពីដើមឆ្នាំនេះមក រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអន្តរាគមន៍ទៅលើជម្លោះដីធ្លីដ៏រ៉ាំរ៉ៃមួយចំនួននៅកម្ពុជា។ នៅចុងខែកុម្ភៈ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសបញ្ចប់ការពិនិត្យលើសម្បទានដីសេដ្ឋកិច្ចដែលមានរយៈពេលយូរឆ្នាំ ដោយបានលើកឡើងថារដ្ឋាភិបាលបានដកហូតផ្ទៃដីទំហំមួយលានហិចតាពីក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចមួយចំនួន (ប៉ុន្តែ តាមការវិភាគទៅលើតួលេខដំបូងបានបង្ហាញថាផ្ទៃដីដែលត្រូវបានដកហូតនោះមិនលើសពី ៧២៦.០០០ ហិចតា[1] នោះទេ)។ នៅកណ្តាលរាជធានីនៃប្រទេសកម្ពុជា គម្រោងអភិវឌ្ឍន៍ចំនួនពីរកន្លែងដែលអាចគំរាមធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋរាប់រយគ្រួសារនោះ ត្រូវបានបញ្ឈប់នៅក្នុងខែមេសា ដោយនាយករដ្ឋមន្ត្រីបានប្រកាសសេចក្តីសម្រេចក្នុងការលុបចោលផែនការសាងសង់ផ្លូវល្បឿនលឿនដែលមានតម្លៃជាច្រើនលានដុល្លារសហរដ្ឋអាមេរិក សម្រាប់ធ្វើដំណើរចេញពីកណ្តាលរាជធានីភ្នំពេញទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ [2] ។ គម្រោងនេះត្រូវបានរដ្ឋាភិបាលប្រកាសជាលើកដំបូងកាលពីខែមករា ប្រសិនបើគម្រោងសាងសង់ផ្លូវល្បឿនលឿននេះនៅតែបន្ត នោះនឹងនាំឱ្យមានផលប៉ះពាល់ដល់ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋរាប់រយគ្រួសារ។ ស្រដៀងគ្នានេះ នៅក្នុងខែមីនា នាយករដ្ឋមន្ត្រីបានលុបចោលគម្រោងពង្រីកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បន្ទាប់ពីមានការតវ៉ា ការដាក់ញត្តិនិងបាតុកម្មរបស់ប្រជាពលរដ្ឋអស់រយៈពេលជិតបួនឆ្នាំកន្លងមក។ គម្រោងនេះធ្វើឡើងក្នុងគោលបំណងធានាឱ្យអាកាសយានដ្ឋានអន្តរជាតិមួយនេះត្រូវបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ប៉ុន្តែអាស្រ័យទៅនឹងការបណ្តេញចេញប្រជាពលរដ្ឋចំនួន១៦៥ គ្រួសារដែលជាម្ចាស់ដីនោះផងដែរ។ អន្តរាគមន៍ទាន់ពេលរបស់

---

[1] ដោយ ហ្សមប៊ិរ ភីធីរ៍ "តួលេខថ្មីអំពីការលុបចោលសម្បទានដីនៅមិនទាន់ច្បាស់លាស់" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦) http://bit.ly/24h72Ay

[2] ពេជ្រ សុធារី និង អាណាន់ បាលីកា "នាយករដ្ឋមន្ត្រីលុបចោលគម្រោងសាងសង់ផ្លូវល្បឿនលឿន ដោយលើកឡើងពីការព្រួយបារម្ភក្នុងដំណើរការសាងសង់" *សារព័ត៌មានភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦) http://bit.ly/1YGs0Fk

នាយករដ្ឋមន្ត្រីក្នុងគម្រោងទាំងនេះបានការពារដល់ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋជាច្រើនរយគ្រួសារ ដែលនេះជាកិច្ចអន្តរាគមន៍គួរឱ្យសាទរ។

ខណៈដែលមានការលុបចោលគម្រោងអភិវឌ្ឍខាងលើនៅក្នុងរាជធានី ត្រូវបានសាទរជាខ្លាំងនោះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមរំលឹកឡើងវិញនូវហានិភ័យផ្នែកពាណិជ្ជកម្មមួយចំនួនក្នុងរាជធានីភ្នំពេញដែលត្រូវបានរដ្ឋាភិបាលបានអនុម័តរួចហើយ ដែលនេះបានគំរាមធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋរាប់ពាន់គ្រួសារ ហើយដែលនេះក៏តម្រូវឱ្យមានអន្តរាគមន៍ជាបន្ទាន់ពីរដ្ឋាភិបាលផងដែរ។ កង្វះការពិគ្រោះយោបល់ជាសាធារណៈ និងកង្វះព័ត៌មានបានធ្វើឱ្យពលរដ្ឋជាច្រើនគ្រួសាររងការគំរាមកំហែងតាមរយៈគម្រោងទាំងនេះ ដែលកាន់តែនាំឱ្យមានការព្រួយបារម្ភទៅលើការបាត់បង់ដីធ្លី និងផ្ទះសម្បែងរបស់ពួកគាត់។ ការព្រួយបារម្ភនេះមិនត្រូវបានមើលឃើញឡើយ ហើយបើតាមសាវតានៃគម្រោងអភិវឌ្ឍរបស់រដ្ឋាភិបាលក្នុងរាជធានីភ្នំពេញគឺបានបង្ខំប្រជាពលរដ្ឋជាច្រើនពាន់គ្រួសារចាកចេញពីផ្ទះសម្បែងជាមួយនឹងសំណងតិចតួច។ ជាការពិតណាស់ ម.ស.ម.ក ទទួលស្គាល់ថាការអភិវឌ្ឍសេដ្ឋកិច្ចគឺមានសារៈសំខាន់សម្រាប់ការរីកចម្រើនរបស់ប្រទេសជាតិ ប៉ុន្តែត្រូវតែគិតពីតម្លៃសិទ្ធិមនុស្សផងដែរ។ សលាកប័ត្រព័ត៌មាននេះនឹងលើកឡើងនូវគម្រោងអភិវឌ្ឍមួយចំនួនក្នុងរាជធានីភ្នំពេញដែលបានគំរាមដល់សិទ្ធិមនុស្ស និងបំពានទៅលើច្បាប់ជាតិនិងច្បាប់អន្តរជាតិ។

សលាកប័ត្រព័ត៌មាននេះតាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការងារដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## កំណើនសេដ្ឋកិច្ចនៅរាជធានីភ្នំពេញ

ចាប់តាំងពីមានការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចទីផ្សារសេរីក្នុងឆ្នាំ១៩៨៩ មក ប្រទេសកម្ពុជាត្រូវបានក្រុមហ៊ុនអាជីវកម្មបរទេសចាត់ទុកជាទីតាំងគួរឱ្យចាប់អារម្មណ៍សម្រាប់ការវិនិយោគ តែដោយសារអស្ថិរភាពនយោបាយនាពេលកន្លងមកនេះ កម្ពុជាគឺជាទីផ្សារមួយដែលពុំទាន់មានលក្ខណៈប្រកួតប្រជែងនៅឡើយ។ ក្រុមហ៊ុនគ្រប់គ្រងដោយបរទេសមួយចំនួនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការដោយមិនចាំបាច់មានដៃគូក្នុងស្រុក ដែលអាចទាញយកផលចំណេញច្រើនសន្ធឹកសន្ធាប់ពីតម្លៃពលកម្មថោក និងដោយសារទីផ្សារសេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារសហរដ្ឋអាមេរិកអាចប្រតិបត្តិការទៅបានដោយពុំមានការបារម្ភពីអត្រាប្រែប្រួលចុះឡើងនៃរូបិយប័ណ្ណ។ មហិច្ឆតាក្នុងការទទួលផលប្រយោជន៍ពីស្ថានភាពធុរកិច្ចអំណោយផលបែបនេះបានធ្វើឱ្យក្រុមហ៊ុនមកពីបណ្តាប្រទេសមួយចំនួនដូចជា វៀតណាម ចិន កូរ៉េខាងត្បូង ថៃ ម៉ាឡេស៊ី ឥណ្ឌា សិង្ហបុរី និងបារាំង បានវិនិយោគយ៉ាងខ្លាំងទៅក្នុងទីផ្សារកម្ពុជានាប៉ុន្មានឆ្នាំចុងក្រោយនេះ។ ម្យ៉ាងទៀត នីតិរដ្ឋទន់ខ្សោយ និងវប្បធម៌នៃអំពើពុករលួយនៅកម្ពុជាបានលើកទឹកចិត្តបន្ថែមដល់វិនិយោគិនដែលជាញឹកញាប់អាចគេចវេះពីការគោរពតាមបទបញ្ញាដែលមានលក្ខណៈរឹតត្បិត និងបង្កផលប៉ះពាល់ដល់លក្ខខណ្ឌវាយតម្លៃដែលប្រទេសជាច្រើនផ្សេងៗទៀតតម្រូវឲ្យអនុវត្តន៍ ។ ខណៈដែលនៅតំបន់ទីក្រុងនៃប្រទេសកម្ពុជាមានប្រជាពលរដ្ឋច្រើនជាង

១០០.០០០នាក់ ភ្នំពេញបានក្លាយជាគោលដៅដ៏សំខាន់សម្រាប់វិនិយោគិនបរទេស ហើយជាទីក្រុងដែលមានការរីកចម្រើនឆាប់រហ័សជាងគេក្នុងចំណោមទីក្រុងនៃបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។[3]

ការផ្លាស់ប្តូរសេដ្ឋកិច្ចនាពេលថ្មីៗរបស់កម្ពុជាបាននាំទៅរកការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់ និងការវិវឌ្ឍន៍ទៅរកជីវភាពមធ្យម ជាមួយឥទ្ធិពលនៃការទិញដូរ កាន់តែធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើនបន្ថែមទៀត។ តួលេខរបស់ធនាគារពិភពលោកបង្ហាញថាក្នុងឆ្នាំ២០០៤ ប្រជាពលរដ្ឋកម្ពុជាចំនួន ៥៣ ភាគរយបានរស់នៅក្រោមបន្ទាត់ក្រីក្រ ហើយនៅក្នុងឆ្នាំ២០១២ តួលេខនេះបានធ្លាក់ចុះមកនៅ ១៧,៧ ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប។[4] ប៉ុន្តែ ខណៈពេលដែលភាពក្រីក្របន្តធ្លាក់ចុះនៅកម្ពុជា ល្បឿននៃការធ្លាក់ចុះក៏មានលក្ខណៈគួរឲ្យកត់សម្គាល់ផងដែរចាប់តាំងពីឆ្នាំ២០១២ ។ បន្ថែមពីលើនេះ គ្រួសារប្រជាពលរដ្ឋមួយចំនួនធំដែលបានគេចផុតពីភាពក្រីក្រអាចរកប្រាក់ចំណូលបានតិចតួចប៉ុណ្ណោះ ហើយប្រឈមនឹងហានិភ័យខ្ពស់ក្នុងការវិលត្រឡប់ទៅរកភាពក្រីក្រវិញ។[5] ម្យ៉ាងទៀត ការវិវឌ្ឍជាវិជ្ជមាននេះត្រូវបានរំខានដោយសារការអភិវឌ្ឍពាណិជ្ជកម្មមិនមាននិរន្តរភាពនៅក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋក្រីក្រនៅមូលដ្ឋាន និងមិនបានផ្តល់សំណងឱ្យបានត្រឹមត្រូវដល់ពលរដ្ឋដែលរងផលប៉ះពាល់ទាំងនោះឡើយ។ លំនៅដ្ឋាននិងបរេចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជាច្រើនពាន់គ្រួសារត្រូវបានខូចខាតក្រោមឈ្មោះអភិវឌ្ឍសេដ្ឋកិច្ច ដោយរដ្ឋាភិបាលមិនបានគោរពនូវតួនាទីរបស់ខ្លួនក្នុងការលើកកម្ពស់និងគោរពសិទ្ធិរបស់ប្រជាពលរដ្ឋឡើយ។

ដោយសារតែអំពើពុករលួយរ៉ាំរ៉ៃក្នុងចំណោមបុគ្គលមានអំណាចនៅកម្ពុជា ក្រុមហ៊ុនដែលមានភាគហ៊ុនជាមួយអ្នកមានអំណាចមួយចំនួន ជារឿយៗត្រូវបានផ្តល់អាទិភាពសំខាន់ជាងសិទ្ធិដីធ្លីរបស់សហគមន៍ដែលងាយរងគ្រោះ។ ហេតុដូច្នោះបានជាមានក្រុមហ៊ុនឯកជនជាច្រើនស្ថិតនៅពីក្រោយគម្រោងអភិវឌ្ឍទាំងនេះដែលអាចធ្វើប្រតិបត្តិការដោយនិទណ្ឌភាពពាក់ព័ន្ធក្នុងការរំលោភសិទ្ធិមនុស្សមូលដ្ឋាន។ ឧទាហរណ៍ក្រុមហ៊ុនឯកជនចំនួនពីរដែលមានពាក់ព័ន្ធនឹងការបណ្តេញនិងរំលោភបំពានសិទ្ធិរបស់ប្រជាពលរដ្ឋនៅតំបន់បឹងកក់ និងបុរីកីឡាក្នុងរាជធានីភ្នំពេញ គឺមានសមាជិកព្រឹទ្ធសភារបស់គណបក្សកាន់អំណាចគឺលោកឧកញ៉ា ឡៅ ម៉េងឃិន ជាសមាជិកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនទាំងនេះ។

## ការអនុវត្តច្បាប់ពុំត្រឹមត្រូវ

តួអង្គសាជីវកម្មជាច្រើនដែលអនុវត្តគម្រោងអភិវឌ្ឍក្នុងរាជធានីកំពុងរំលោភទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ដូចមានគូសបញ្ជាក់នៅក្នុងអនុក្រឹត្យលេខ១៤៦ ចេញនៅឆ្នាំ២០១៤ ស្តីពីសម្បទានដីសេដ្ឋកិច្ច រដ្ឋាភិបាលអាចជួលដីឯកជនរបស់រដ្ឋទៅឱ្យក្រុមហ៊ុនឯកជនប្រើប្រាស់ក្នុងគោលបំណងអភិវឌ្ឍកសិឧស្សាហកម្ម

---

[3] ដោយ Eddie Morton "ក្រុងភ្នំពេញត្រូវបានពង្រីកយ៉ាងលឿននៅក្នុងតំបន់" សារព័ត៌មានភ្នំពេញ ថ្ងៃអង្គារ៍ ទី២៧ ខែមករា ឆ្នាំ ២០១៥ http://bit.ly/1qIBFQq

[4] ធនាគារពិភពលោក "ភាពក្រីក្របានធ្លាក់ចុះ..." (ឆ្នាំ២០១៤) http://bit.ly/1hdZ0R5 និងទិន្នន័យធានាគារពិភពលោក http://bit.ly/232cBAv

[5] ប្រភពខាងលើ

សម្រាប់រយៈពេលរហូតដល់ ៩៩ ឆ្នាំ[6] ទោះជាយ៉ាងណា កាលពីឆ្នាំមុនរដ្ឋាភិបាលបានប្រកាសពីគោលបំណងកាត់បន្ថយកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចទាំងអស់មកនៅត្រឹមរយៈពេល ៥០ ឆ្នាំ[7]។ មាត្រា ៤ នៃអនុក្រឹត្យលេខ១៤៦ ចែងថា សម្បទានដីសេដ្ឋកិច្ចអាចត្រូវផ្តល់ឱ្យចំពោះតែដីដែលមានលក្ខណៈវិនិច្ឆ័យប្រាំយ៉ាងដូចជា (១)ជាដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីរបស់រដ្ឋ (២)ដីដែលមានផែនការប្រើប្រាស់ អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ ខេត្ត ក្រុង (៣) ដីដែលបានធ្វើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គមរួចរាល់ហើយ (៤)មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន និង(៥) ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់[8] ។ ប៉ុន្តែ ការអនុវត្តជាក់ស្តែងលក្ខណៈវិនិច្ឆ័យទាំងនេះកម្រត្រូវបានគេគោរពតាម ហេតុដូច្នេះ គម្រោងដែលកំពុងដំណើរការក្នុងរាជធានីភ្នំពេញបានរំលោភទៅលើច្បាប់ជាតិ។

ឧទាហរណ៍ នៅក្នុងឆ្នាំ២០០៧ សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុនស៊ូកាគូអ៊ីរបស់សមាជិកព្រឹទ្ធសភាគណបក្សកាន់អំណាចគឺលោកឧកញ៉ា ឡៅ ម៉េងឃិន ដើម្បីធ្វើការអភិវឌ្ឍតំបន់បឹងកក់ក្នុងរាជធានីភ្នំពេញ និងនៅតំបន់ជុំវិញនោះឱ្យក្លាយទៅជា *"ទីក្រុងទំនើបដែលមានភូមិគ្រឹះ និងអាគារពាណិជ្ជកម្មប្រណិត"*[9]។ ការផ្តល់សម្បទាននោះធ្វើឡើងដោយពុំបានធ្វើការប្រឹក្សាយោបល់ជាសាធារណៈជាមួយដៃគូពាក់ព័ន្ធនៅមូលដ្ឋានឡើយ ហើយរដ្ឋាភិបាលខកខានក្នុងការចេញផ្សាយនូវលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់ផ្នែកបរិស្ថាននិងសង្គមរហូតទាល់តែការងារនោះចាប់ផ្តើមដូច្នេះសម្បទាននោះពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងអនុក្រឹត្យលេខ ១៤៦ ឡើយ[10]។ ម្យ៉ាងទៀត នៅពេលផ្តល់សម្បទានដីនោះត្រូវបានរកឃើញថា "ជាដីសាធារណៈរបស់រដ្ឋ" ដូច្នេះតាមច្បាប់មិនគ្រប់លក្ខខណ្ឌសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចឡើយ។[11]

ស្រដៀងគ្នានេះ សកម្មភាពរបស់ក្រុមហ៊ុនផានអ៊ីមិចជាប់ពាក់ព័ន្ធក្នុងការអភិវឌ្ឍនៅបុរីកីឡាឆ្លុះបញ្ចាំងឱ្យឃើញពីការមិនគោរពច្បាប់។ កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងក្រុមហ៊ុនផានអ៊ីមិចនៅក្នុងឆ្នាំ២០០៣ ធ្វើឡើងពីដំបូងជា "កិច្ចព្រមព្រៀងចែករំលែកដី" ដោយត្រឹមតែផ្តល់សិទ្ធិអភិឌ្ឍលើផ្ទៃដីទំហំ ២,៦ ហិចតាប៉ុណ្ណោះតាមរយៈសម្បទានដីសង្គមកិច្ច ដោយក្រុមហ៊ុនបានសន្យាថានឹងសាងសង់អគារចំនួន ១០ នៅលើផ្ទៃដីពីរហិចតាជូនដល់ប្រជាពលរដ្ឋនៅបុរីកីឡា។ ប៉ុន្តែ ក្រុមហ៊ុនផានអ៊ីមិចពុំបានគោរពតាមកិច្ចព្រមព្រៀងនោះឡើយ

---

[6] អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច http://bit.ly/1sXh06e

[7] សេចក្តីថ្លែងការណ៍លេខ៦៨៣ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ចេញផ្សាយដោយក្រសួងបរិស្ថានបានប្រកាសថា រដ្ឋាភិបាលបានសម្រេចជាគោលការណ៍ក្នុងការបន្ថយកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចទាំងអស់មកនៅត្រឹមរយៈពេល ៥០ឆ្នាំ។

[8] អនុក្រឹត្យលេខ១៤៦ ស្តីពីសម្បទានដីសេដ្ឋកិច្ច មាត្រា៤ http://bit.ly/1sXh06e

[9] សលាកប័ត្រព័ត៌មានរបស់ ម.ស.ម.ក កម្រងករណីសិក្សា "បឹងកក់" http://bit.ly/1TxnJGe

[10] ស៊ុយហៀង គ្រី "គម្រោងអភិវឌ្ឍបឹងកក់៖ ដើម្បីនរណា និងគោលបំណងអ្វី? ការអភិវឌ្ឍដីមានលក្ខណៈទន់ខ្សោយគឺជាបញ្ហាប្រឈមមួយសម្រាប់ការកសាងសន្តិភាពជានិរន្តរ៍នៅកម្ពុជា" ច្បាប់កម្ពុជា និងសៀវភៅគោលនយោបាយ ចេញផ្សាយ លេខ៣ (ខែធ្នូ ឆ្នាំ២០១៤) http://bit.ly/1TLQZYy

[11] ប្រភពខាងលើ

ហើយនៅក្នុងខែមេសា ឆ្នាំ២០១០ បន្ទាប់ពីបានសាងសង់អគារប្រាំបីក្នុងចំណោមអគារចំនួន១០ ក្រុមហ៊ុនបានប្រកាសថាក្សយធនមិនអាចសាងសង់លំនៅដ្ឋានឱ្យបានគ្រប់ចំនួនជូនដល់ពលរដ្ឋឡើយ ដោយបន្សល់ទុកពលរដ្ឋចំនួន ៣០០ គ្រួសារគ្មានផ្ទះសម្បែង។ ភាគច្រើននៃប្រជាពលរដ្ឋទាំងនេះបានប្តូរទៅកាន់ទីតាំងថ្មី ប៉ុន្តែពលរដ្ឋជាច្រើនគ្រួសារបានវិលត្រឡប់មកកាន់បុរីកីឡាវិញដោយរស់នៅក្រោមខ្ទមបណ្តោះអាសន្ន ព្រោះថាស្ថានភាពរស់នៅលើទីតាំងថ្មីនោះមិនល្អទាល់តែសោះសម្រាប់ពួកគាត់។ បន្ទាប់ពីរង់ចាំដំណោះស្រាយអស់រយៈពេលជិតបួនឆ្នាំមក នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ មានការសម្រេចជាចុងក្រោយថាមានប្រជាពលរដ្ឋតែ ៣៥ គ្រួសារប៉ុណ្ណោះមានសិទ្ធិទទួលបានលំនៅដ្ឋាននៅបុរីកីឡា។ ពលរដ្ឋចំនួន ៨៥ គ្រួសារត្រូវបានជូនដំណឹងថាអាចប្តូរទីតាំងទៅកាន់ភូមិអណ្តូងស្ថិតនៅជាយរាជធានីភ្នំពេញជាទីកន្លែងដែល ម.ស.ម.ក ធ្លាប់បានលើកឡើងថាជាទីតាំងដែលមិនមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់[12] ឬទទួលប្រាក់សំណងចំនួន ៥.០០០ ដុល្លារសហរដ្ឋអាមេរិក។ ប្រជាពលរដ្ឋចំនួន ៣៤គ្រួសារទៀតដែលមិនមានឯកសារបញ្ជាក់គ្រប់គ្រាន់ថាជាអតីតអ្នកបុរីកីឡាបានទទួលសំណងត្រឹមតែ ៣.០០០ ដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះ។ ប្រជាពលរដ្ឋទាំងនោះបាត់បង់នូវទ្រព្យសម្បត្តិទាំងស្រុងនិងមានការខកចិត្តជាខ្លាំង[13] ។ ប្រាក់សំណងបន្ថែមមិនត្រូវបានផ្តល់ជូនឡើយចាប់តាំងពីពេលនោះ ដែលនាំឱ្យគ្រួសាររងផលប៉ះពាល់ដែលសេសសល់មួយចំនួនបន្តដាក់ញត្តិទៅកាន់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅរាជធានីភ្នំពេញ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ដើម្បីស្នើអន្តរាគមន៍ពីអង្គការសហប្រជាជាតិឱ្យជួយពួកគាត់។[14]

ម្យ៉ាងវិញទៀត ក្រុមហ៊ុនពាក់ព័ន្ធក្នុងគម្រោងអភិវឌ្ឍ ជារឿយៗរំលោភទៅលើច្បាប់ភូមិបាលឆ្នាំ២០០១ របស់ប្រទេសកម្ពុជា ដែលតាមទ្រឹស្តីការពារយ៉ាងទូលំទូលាយទៅលើសិទ្ធិដីធ្លី។ សិទ្ធិស្តីពីកម្មសិទ្ធិមានចែងក្នុងមាត្រា ៥ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថា *"គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។"* ច្បាប់នេះចែងបន្ថែមទៀតថា *"ការដកហូតត្រូវតែធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់និងបទបញ្ញាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌"* [15] ។ ប៉ុន្តែជារឿយៗក្រុមហ៊ុនពាក់ព័ន្ធក្នុងគម្រោងអភិវឌ្ឍបានចូលរួមក្នុងការគំរាមកំហែង និងអំពើហិង្សាជាប្រព័ន្ធក្នុងគោលបំណងពន្លឿនឱ្យមានការបន្លាស់ទីសម្រាប់អ្នកភូមិ រហូតដល់ដំណើរការសាងសង់ទាំងមូល។ ទង្វើបែបនេះ ក្រុមហ៊ុនបានរំលោភទៅលើសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ សិទ្ធិសុវត្ថិភាពក្នុងការកាន់កាប់ និងការប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំ។

ការរំលោភបំពាននេះមិនត្រឹមតែផ្ទុយទៅនឹងច្បាប់ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំពានទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលកម្ពុជាជាប់កាតព្វកិច្ចអនុវត្តដោយផ្ទាល់តាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណា

[12] របាយការណ៍របស់ ម.ស.ម.ក "ដីមានទំនាស់៖ ទិដ្ឋភាពនៃស្ថានភាពដីធ្លី" (ខែធ្នូ ឆ្នាំ២០១៣) http://bit.ly/27S2iUH
[13] សលាកប័ត្រព័ត៌មានរបស់ ម.ស.ម.ក "បុរីកីឡា ទំនាស់ដ៏រ៉ាំរ៉ៃនៅតែបន្ត" (ខែធ្នូ ឆ្នាំ២០១៥) http://bit.ly/1YYctRN
[14] សេក ឧត្តម "ក្រោយពីសាលាក្រុងមិនយកចិត្តទុកដាក់ ប្រជាពលរដ្ឋដែលត្រូវបណ្តេញចេញស្នើអង្គការសហប្រជាជាតិឱ្យជួយ"
[15] ច្បាប់ភូមិបាល (ឆ្នាំ២០០១) មាត្រា ៥ http://bit.ly/22oExj7

ចក្រកម្ពុជាដែលបញ្ចូលនូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិកម្ពុជា[16] តាមសេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងឆ្នាំ២០០៧[17]។

ការអភិវឌ្ឍសេដ្ឋកិច្ចមានសក្តានុពលក្នុងការនាំមកនូវផលប្រយោជន៍ខ្លាំងដល់សង្គម ហើយ ម.ស.ម.ក យល់ថាការអភិវឌ្ឍខ្លះតម្រូវឲ្យមានការបណ្តេញចេញ ប៉ុន្តែដើម្បីឱ្យការបណ្តេញចេញនោះមានលក្ខណៈស្របច្បាប់ លុះត្រាតែធ្វើឡើងជាជម្រើសចុងក្រោយហើយត្រូវតែអនុលោមតាមច្បាប់។ យោងតាមគណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់អង្គការសហប្រជាជាតិ នៅមុនពេលមានការបណ្តេញចេញត្រូវតែធ្វើការប្រឹក្សាយោបល់ជាមួយពលរដ្ឋដែលត្រូវបណ្តេញចេញ ធ្វើការជូនដំណឹងឱ្យបានត្រឹមត្រូវដល់ពួកគេ និងផ្តល់សំណងសមរម្យ[18]។ ក្នុងអំឡុងពេលបណ្តេញចេញនោះ ត្រូវតែមានវត្តមានរបស់អាជ្ញាធរ ហើយជនដែលអនុវត្តការបណ្តេញចេញត្រូវបានកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវ[19] ។ លើសពីនេះ ការបណ្តេញចេញមិនត្រូវធ្វើឱ្យប៉ះពាល់ដល់លំនៅដ្ឋានរបស់បុគ្គលទេ ហើយត្រូវតែផ្តល់សំណងស្របតាមច្បាប់ទៅដល់សហគមន៍ដែលរងផលប៉ះពាល់ទាំងនោះ[20]។ គោលការណ៍ណែនាំស្តីពីការ បណ្តេញចេញមួយចំនួនផ្សេងទៀត ក្នុងនោះមានគោលការណ៍មូលដ្ឋាននិងសេចក្តីណែនាំស្តីពីការបណ្តេញចេញនិងការបន្លាស់ទីដើម្បីការអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ[21] និងសលាកប័ត្រព័ត៌មានលេខ ២៥ របស់អង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញដោយបង្ខំ[22]ក៏ចែងពីការរឹតត្បិតស្រដៀងគ្នានេះផងដែរ។ ការបណ្តេញចេញដោយបង្ខំ ការបណ្តេញចេញធ្វើឡើងប្រឆាំងទៅនឹងឆន្ទៈរបស់អ្នកកាន់កាប់ដោយមិនមានបំណងនិងទទួលយកតាមទម្រង់ផ្លូវច្បាប់សមស្រប ឬកិច្ចការពារដទៃទៀត[23] បង្កឱ្យមានការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សរំលោភទៅលើសិទ្ធិមានលំនៅដ្ឋានសមរម្យ សិទ្ធិទទួលបានសុវត្ថិភាពកាន់កាប់ដីធ្លី សិទ្ធិទទួលបានសុវត្ថិភាពផ្ទាល់ខ្លួន សេរីភាពរួចផុតពីអំពើឃោរឃៅ អមនុស្សធម៌ និងអំពើធ្វើឱ្យអាប់ឱន ព្រមទាំងផ្ទុយទាំងស្រុងទៅនឹងបទដ្ឋានសិទ្ធិមនុស្សដែលទទួលស្គាល់ជាអន្តរជាតិ[24]។

---

[16] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១

[17] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

[18] CESR សេចក្តីពន្យល់ទូទៅលេខ៧ ៖ សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ (មាត្រា១១.១) ៖ ការបណ្តេញចេញដោយបង្ខំ ង/១៩៩៨/២២(២០ ឧសភា ឆ្នាំ១៩៩៧)៧,១៣,១៤ និង១៥ http://bit.ly/HbQDIV ។

[19] ប្រភពខាងលើ ១៥

[20] ប្រភពខាងលើ ១៦

[21] គោលការណ៍មូលដ្ឋាន និងសេចក្តីណែនាំស្តីពីការបណ្តេញចេញ និងការបន្លាស់ទីដើម្បីការអភិវឌ្ឍរបស់អ.ស.ប ឧបសម្ព័ន្ធ១ នៃរបាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីលំនៅដ្ឋានសមរម្យជាធាតុផ្សំមួយសិទ្ធិទទួលបានស្តង់ដាររស់នៅសមរម្យ a/HRC/4/18 http://bit.ly/1SPR8VH

[22] សលាកប័ត្រព័ត៌មានរបស់ អ.ស.ប ស្តីពី "ការបណ្តេញចេញដោយបង្ខំ" លេខ២៥ ដំណោះស្រាយ ១ (២០១៤) http://bit.ly/1NKzQKM

[23] សេចក្តីពន្យល់ទូទៅលេខ៧ របស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ៖ សិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ (មាត្រា១១.១) ៖ ការបណ្តេញចេញដោយបង្ខំ E/១៩៩៨/២២(២០ ឧសភា ឆ្នាំ១៩៩៧)៧ http://bit.ly/HbQDIV

[24] ប្រភពខាងលើ

## ការអភិវឌ្ឍសេដ្ឋកិច្ចដោយមិនគិតគូរដល់សិទ្ធិមនុស្ស

ខណៈដែលគោលការណ៍ណែនាំមានលក្ខណៈតឹងរ៉ឹងអំពីការបណ្តេញចេញមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ គួរឱ្យសោកស្តាយដែលមានគម្រោងអភិវឌ្ឍជាច្រើនក្នុងរាជធានីភ្នំពេញនៅប៉ុន្មានឆ្នាំចុងក្រោយនេះមិនបានគោរពដល់គោលការណ៍ទាំងនេះ។ មានការបណ្តេញចេញដោយបង្ខំជាច្រើនបានកើតឡើងនៅទូទាំងទីក្រុងដើម្បីបើកផ្លូវសម្រាប់ការអភិវឌ្ឍ ហើយជាលទ្ធផលធ្វើឱ្យប្រជាពលរដ្ឋជាច្រើនពាន់គ្រួសារបាត់បង់ផ្ទះសម្បែង។ ផ្នែកនេះនឹងលើកឡើងតែករណីចំនួនពីបីប៉ុណ្ណោះក្នុងចំណោមករណីជម្លោះដីធ្លីជាច្រើនក្នុងរាជធានីភ្នំពេញដែលសិទ្ធិមនុស្សត្រូវបានគេចាត់ទុកជាបញ្ហាបន្ទាប់បន្សំជាងការអភិវឌ្ឍសេដ្ឋកិច្ច។

### ករណីបុរីកីឡា

គ្មានផលប៉ះពាល់នៃការបណ្តេញចេញដោយបង្ខំណាមានលក្ខណៈធ្ងន់ធ្ងរជាងករណីបុរីកីឡានោះទេ។ នៅថ្ងៃទី០៣ និងទី០៤ ខែមករា ឆ្នាំ២០១២ ប្រជាពលរដ្ឋដែលសេសសល់នៅបុរីកីឡាត្រូវបានបណ្តេញចេញពីផ្ទះដោយហិង្សាពីសំណាក់កងសន្តិសុខរបស់ក្រុមហ៊ុនផានអ៊ីមិច និងនគរបាលប្រដាប់ដោយគ្រឿងចក្រ ដំបងឆក់ និងឧស្ម័នបង្ហូរទឹកភ្នែក។ ក្នុងអំឡុងការបណ្តេញចេញនោះមានផ្ទះសម្បែងជាង២០០ ខ្នងត្រូវបានកម្ទេចចោល ហើយប្រជាសហគមន៍ជាច្រើននាក់បានរងរបួស និងត្រូវបានឃុំខ្លួន។ ការចូលរួមពីប៉ូលីស និងកងរាជអាវុធហត្ថជានិច្ចកាលក្នុងការបង្ក្រាបដោយហិង្សាទៅលើអ្នកតវ៉ានៅបុរីកីឡា ដែលថាជាសកម្មភាពខុសច្បាប់នេះតែងមានការគាំទ្រពីសំណាក់រដ្ឋាភិបាល[25]។

លើសពីនេះ ទីតាំងថ្មីសម្រាប់ផ្តល់ជូនដល់ពលរដ្ឋដែលត្រូវបណ្តេញចេញនោះ ជារឿយៗជាតំបន់ដាច់ស្រយាល ហើយម្យ៉ាងទៀតជាកន្លែងមិនអាចរស់នៅបាន ដែលកាន់តែនាំឱ្យមានការរំលោភបំពានសិទ្ធិមនុស្សបន្ថែមទៀត។ ភាគច្រើននៃគ្រួសាររស់នៅបុរីកីឡាត្រូវបានប្តូរទៅកាន់ទីតាំងដាច់ស្រយាលពីរកន្លែងគឺ ទួលសំបូរមានចម្ងាយ ២៥ គីឡូម៉ែត្រពីរាជធានីភ្នំពេញ ក្នុងឃុំព្រៃវែង និងស្រែពោធិ៍ (ឬហៅភ្នំបាត) មានចម្ងាយ ៤៥ គីឡូម៉ែត្រពីភ្នំពេញស្ថិតនៅក្នុងខេត្តកណ្តាល។ ចាប់តាំងពីពេលនោះមកពលរដ្ឋដែលត្រូវបានបណ្តេញចេញបានរស់នៅក្រោមកៅស៊ូតង់ជាបណ្តោះអាសន្ននៅលើទីតាំងថ្មីទាំងនេះ ហើយបានប្រឈមនឹងបញ្ហាជាច្រើនដូចជា កង្វះភ្លើងអគ្គិសនី បង្គន់អនាម័យ ទឹកស្អាត សាលារៀន និងឱកាសការងារ។ សំរាមគរឡើងកាន់តែច្រើន និងបរិស្ថានមិនល្អបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់ពលរដ្ឋទាំងនោះ។ ទីតាំងថ្មីទាំងនេះមិនស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីការបណ្តេញចេញដើម្បីការអភិវឌ្ឍ ជាការផ្ទុយទៅនឹងច្បាប់ជាតិនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិមួយចំនួន និងមិនបានបំពេញតាមលក្ខខ័ណ្ឌសម្រាប់គម្រោងអភិវឌ្ឍដូចមានចែងក្នុងច្បាប់ភូមិបាលឡើយ។

### ករណីបឹងកក់

នៅពេលដែលជនរងគ្រោះនៃអំពើរំលោភបំពានសិទ្ធិមនុស្សបានព្យាយាមស្វែងរកសំណង ពួកគេបានរងការបំពារបំពានបន្ថែមទៀត។ បន្ទាប់ពីធ្វើបន្លាស់ទីដោយមិនស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋជាច្រើនពាន់គ្រួសារ

---

25 សលាកប័ត្រព័ត៌មានរបស់ ម.ស.ម.ក "បុរីកីឡា ទំនាស់ដ៏រ៉ាំរ៉ៃនៅតែបន្ត" (ខែធ្នូ ឆ្នាំ២០១៥) http://bit.ly/1YYctRN

រស់នៅជុំវិញបឹងកក់ ដែលអង្គការលើកលែងទោសអន្តរជាតិចាត់ទុកថាជាការបណ្តេញចេញដោយបង្ខំមានទ្រង់ទ្រាយធំក្នុងប្រទេស ចាប់តាំងពីការជម្លៀសពលរដ្ឋចេញពីភ្នំពេញក្នុងរបបខ្មែរក្រហមឆ្នាំ១៩៧៥[26] គ្រួសារទាំងនោះបានព្យាយាមម្តងហើយម្តងទៀតដើម្បីទាមទារសិទ្ធិរបស់ខ្លួន។ ឧទាហរណ៍កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១ អ្នកភូមិជាច្រើននាក់ រួមមានកុមារចំនួនពីរនាក់ផងបានធ្វើដំណើរទៅកាន់សាលារាជធានីភ្នំពេញដើម្បីប្រើប្រាស់សេរីភាពខាងការបញ្ចេញមតិ និងការប្រមូលផ្តុំរបស់ខ្លួន និងចូលរួមក្នុងកិច្ចពិភាក្សាប្រកបដោយអត្ថន័យជាមួយអាជ្ញាធរមូលដ្ឋាន ដោយសង្ឃឹមថានឹងបញ្ឈប់នូវសកម្មភាពបូមខ្សាច់ចាក់លុបបឹងកក់ និងដើម្បីស្វែងរកដំណោះស្រាយក្នុងជម្លោះនោះ។ តែផ្ទុយមកវិញ ពួកគាត់រងការវាយដំដោយដំបងឆក់និងត្រូវបានកងសន្តិសុខរាជធានីភ្នំពេញឃុំខ្លួន ដែលធ្វើឱ្យស្ត្រីចំណាស់អាយុ ៧១ ឆ្នាំម្នាក់បានរងរបួសក្បាលជាទម្ងន់ ហើយស្ត្រីម្នាក់ផ្សេងទៀតបានបាក់មេដៃ។ ស្ត្រី ៩ នាក់ត្រូវបានចាប់និងឃុំខ្លួនដោយខុសច្បាប់ ហើយត្រូវបានបង្ខិតបង្ខំឱ្យចុះកិច្ចសន្យាទទួលខុសត្រូវចំពោះអំពើហិង្សា[27]។ ករណីជាច្រើនសកម្មជនបឹងកក់ត្រូវបានចាប់ខ្លួននិងដាក់ពន្ធនាគារដោយសារការតវ៉ាដោយសន្តិវិធីដែលជាការរំលោភទៅលើសិទ្ធិសេរីភាពខាងប្រមូលផ្តុំ និងខាងការបញ្ចេញមតិ។ សកម្មជនបឹងកក់ជាស្ត្រីមួយរូបត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេលបីឆ្នាំដោយសារការប្រឆាំងតវ៉ាចំពោះការអភិវឌ្ឍន៍បឹងនៅក្នុងខែធ្នូឆ្នាំ២០១២ និងបើទោះជាមានការថ្កោលទោសជាអន្តរជាតិជុំវិញការកាត់ទោសរូបនាងក៏ដោយ លុះដល់ខែវិច្ឆិកា ឆ្នាំ២០១៣ នាងទើបត្រូវបានដោះលែងវិញ។ ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែមេសា ឆ្នាំ២០១៥ សកម្មជនបឹងកក់ចំនួនប្រាំពីររូបត្រូវបានដាក់ពន្ធនាគារដោយសារពាក់ព័ន្ធក្នុងការតវ៉ាស្របច្បាប់ និងដោយសន្តិវិធីទៅនឹងការបំផ្លិចបំផ្លាញសហគមន៍របស់ពួកគេ។ ប្រសិនបើរដ្ឋាភិបាលមានបំណងធានានូវតុល្យភាពរវាងផលប្រយោជន៍សេដ្ឋកិច្ច និងការការពារសិទ្ធិមនុស្សមែននោះ ការរំលោភបំពានសិទ្ធិមនុស្សជាក់ស្តែងនេះមិនគួរបន្តឱ្យកើតមានឡើងទៀតនោះទេ។

ខណៈដែលករណីនេះហួសពីវិសាលភាពនៃសលាកប័ត្រព័ត៌មាននេះក្នុងការដាក់ជាចំណោទបញ្ហាមែនថាតើគម្រោងអភិវឌ្ឍនេះពិតជាផ្តល់ផលប្រយោជន៍ដល់សាធារណជនធំធេងឬយ៉ាងណា នេះបង្ហាញច្បាស់ថាសំណងផ្តល់ជូនអ្នកភូមិជារឿយៗមិនស្របទៅនឹងបទដ្ឋានច្បាប់ជាតិនិងអន្តរជាតិ។ អ្នកភូមិបឹងកក់ត្រូវបានផ្តល់ជូនសំណងតាមរយៈជម្រើសចំនួនបី ៖ (១)ទទួលប្រាក់ចំនួន ៨.៥០០ ដុល្លារសហរដ្ឋអាមេរិក (២) ទទួលលំនៅដ្ឋាននៅលើទីតាំងថ្មីនៅដំណាក់ត្រយឹង ចម្ងាយ ២០ គីឡូម៉ែត្រពីទីក្រុង ឬសន្យាសាងសង់លំនៅដ្ឋានលើទីតាំងនោះ និង (៣) ប្តូរទីលំនៅទៅកាន់ត្រពាំងអញ្ចាញចម្ងាយ ២០ គីឡូម៉ែត្រពីទីក្រុង ដោយរស់នៅទីនោះអស់រយៈពេលបួនឆ្នាំនឹងទទួលបានលំនៅដ្ឋានថ្មី។ សំណងជាទឹកប្រាក់ចំនួន ៨.៥០០ ដុល្លារសហរដ្ឋអាមេរិក ដែលផ្តល់ជូនពលរដ្ឋនោះមិនស្របទៅនឹងតម្លៃដីលើទីផ្សារនាពេលនោះទេ ហើយមិនបានផ្តល់ជូនជាមុនដូចមានចែងក្រោមច្បាប់ភូមិបាលឡើយ។

[26] អង្គការលើកលែងទោសអន្តរជាតិ "ការបណ្តេញ និងការតវ៉ានៅកម្ពុជា ៖ ស្ត្រីប្រាំរូបរៀបរាប់ពីរឿងរ៉ាវរបស់ពួកគេ(២០១១) http://bit.ly/1TiHRWI

[27]សលាកប័ត្រព័ត៌មានរបស់ ម.ស.ម.ក កម្រងករណីសិក្សា "បឹងកក់" (ខែតុលា ឆ្នាំ២០១១) http://bit.ly/1TxnJGe

## ករណីបឹងទំពន់ និងបឹងជើងឯក

ទោះបីជាមានការរំលោភសិទ្ធិជាច្រើនបានកើតឡើងក្នុងរាជធានីភ្នំពេញដោយសារគម្រោងអភិវឌ្ឍ ហើយជនរងគ្រោះភាគច្រើនមិនទាន់ទទួលបានសំណងត្រឹមត្រូវក៏ដោយ ក៏រដ្ឋាភិបាលនៅតែបន្តយល់ព្រមលើគម្រោងបន្ថែមទៀតដែលបានគំរាមដល់សិទ្ធិរបស់អ្នកភូមិ។ ការអភិវឌ្ឍទីក្រុងរណបកំពុងស្ថិតនៅក្រោមគម្រោងសាងសង់នៅបឹងទំពន់ និងបឹងជើងឯកដែលធ្វើឱ្យហូរច្រោះដីពីតំបន់សំណើម ដែលនេះជាករណីឧទាហរណ៍មួយ។ ការអភិវឌ្ឍបានចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០០៩ ហើយកាន់តែធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារ និងគំរាមដល់ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តចំពោះប្រជាពលរដ្ឋដែលនៅសេសសល់ទាំងនោះ ទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងររួចទៅហើយ ព្រោះការចាក់ខ្សាច់បំពេញបឹងបានរាំងបឹងក្នុងការបំពេញមុខងារសំខាន់របស់ខ្លួន ដែលជាប្រភពរំដោះទឹកកខ្វក់និងជាប្រព័ន្ធគ្រប់គ្រងទឹកជន់លិចសម្រាប់រាជធានីភ្នំពេញ។ តាំងពីការអភិវឌ្ឍបានចាប់ផ្តើម ការជន់លិចនៅក្នុងទីក្រុងកាន់តែខ្លាំងឡើងហើយអ្នកភូមិក្នុងតំបន់នោះបានទទួលរងគ្រោះដោយសារកម្រិតទឹកកខ្វក់កើនឡើងមិនស្រកចុះ។[28] កង្វះការប្រឹក្សាយោបល់ជាសាធារណៈ និងកង្វះព័ត៌មានបាននាំឱ្យពលរដ្ឋជាច្រើនគ្រួសារបារម្ភពីការបាត់បង់ផ្ទះសម្បែងរបស់ពួកគាត់ ហើយរបាយការណ៍លើកឡើងថាក្រុមហ៊ុនសាងសង់បានព្រមានគ្រួសារទាំងនោះថាប្រសិនបើពួកគាត់បដិសេធសំណងនោះ ពួកគាត់នឹងត្រូវបណ្តេញចេញដោយបង្ខំហើយនឹងមិនទទួលបានសំណងអ្វីទាំងអស់[29]។

## ករណីបឹងត្របែក

ដោយសារតែសេចក្តីសម្រេចរបស់សាលារាជធានីភ្នំពេញក្នុងការស្តារបឹងត្របែក ប្រជាពលរដ្ឋរស់នៅជុំវិញតំបន់នោះកំពុងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនស្រដៀងគ្នានឹងប្រជាពលរដ្ឋរស់នៅក្នុងតំបន់បឹងទំពន់ដែរ។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៥ ដោយពុំបានចូលរួមក្នុងកិច្ចពិភាក្សាពិគ្រោះយោបល់ជាមុនជាមួយអ្នកភូមិ អាជ្ញាធរមូលដ្ឋានបានបាញ់ថ្នាំជាលេខពណ៌ក្រហមនៅលើខ្ទមបណ្តោះអាសន្នក្នុងភូមិផ្សារដើមថ្កូវក្នុងខណ្ឌចំការមន ដើម្បីសម្គាល់តំបន់ផ្ទះសម្រាប់ធ្វើការរុះរើចេញ។ មិនដូចទៅនឹងការបណ្តេញចេញផ្សេងៗដែលធ្វើឡើងដើម្បីអនុញ្ញាតឱ្យមានការសាងសង់ផ្ទះល្វែងប្រណិតៗនោះទេ ការបណ្តេញចេញទាំងនេះធ្វើឡើងក្នុងគោលបំណងស្តារបឹងត្របែកដើម្បីកាត់បន្ថយការជន់លិចទឹកនៅក្នុងតំបន់នេះ។ ការជន់លិចពិតជាបញ្ហាសំខាន់ណាស់ក្នុងតំបន់នេះ និងអាចនាំឱ្យមានផលប៉ះពាល់ដល់សុខភាពរបស់ពលរដ្ឋដែលរស់នៅតាមបណ្តោយលូទឹកស្អុយ។ នៅរដូវវស្សា *"សំរាមកកស្ទះ ក្រោមស្ពាន"* បណ្តាលឱ្យទឹកឡើងខ្ពស់យ៉ាងឆាប់រហ័ស "រហូតទាល់មានកក់ខ្មៅកខ្វក់ចូលពាសពេញផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ" [30] ។ ការស្តារបឹងត្របែកឡើងវិញនោះត្រូវបាន

---

[28] ព្រឹត្តិប័ត្រព័ត៌មានរបស់សមាគមធាងត្នោត Facts & Figures # 25 "បឹងទំពន់" ៖ អនាគតមិនប្រាកដ http://bit.ly/247bHTN

[29] ប្រភពខាងលើ

[30] ហូប៊ី ដឺនីស (Hruby, Denise) "ប្រជាពលរដ្ឋនៅសហគមន៍បឹងត្របែកចំនួន៤០០គ្រួសារត្រៀមលក្ខណៈជម្លៀសចេញ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៥) http://bit.ly/1OhAcZ4

បកស្រាយថាជាគម្រោងមួយដែលលើកកម្ពស់ "សុខុមាលភាពទូទៅ" របស់ប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ ដូច្នេះហើយជាការបណ្ដេញចេញដើម្បីការអភិវឌ្ឍដែលសមហេតុផលតាមផ្លូវច្បាប់ អនុលោមតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ[31]។ ប៉ុន្តែបើទោះបីជាមានហេតុផលសមរម្យចំពោះ ការបណ្ដេញចេញទាំងនេះក្ដី សាលារាជធានីក៏នៅតែជាប់កាតព្វកិច្ចតាមក្របខ័ណ្ឌច្បាប់ជាតិនិងអន្តរជាតិក្នុងការគោរពដល់គោលការណ៍នៃការពិគ្រោះយោបល់ សំណង និងនីតិសម្បទាដោយយុត្តិធម៌ត្រឹមត្រូវ។ រហូតមកទល់ពេលនេះ ករណីនោះមិនទាន់សម្រេចយ៉ាងណានៅឡើយ ព្រោះមានការប្រឹក្សាយោបល់តិចតួចហើយការផ្ដល់ជូនសំណងរបស់សាលាក្រុងដល់អ្នកភូមិនៅក្រោមតម្លៃទីផ្សារ[32]។

## ករណីតំបន់ជ្រោយចង្វារ

ផែនការស្ដាបនាផ្លូវចម្ងាយ១០០ ម៉ែត្រនៅភាគខាងលិចផ្លូវជាតិលេខ ៦ បង្ហាញនូវឧទាហរណ៍ផ្សេងមួយទៀតនៃការពាក់ព័ន្ធរបស់សាលាក្រុងក្នុងករណីបណ្ដេញប្រជាពលរដ្ឋដ៏ចម្រូងចម្រាសដើម្បីការអភិវឌ្ឍ និងជាការឆ្លុះបញ្ចាំងឱ្យឃើញពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍក្នុងទីក្រុង ដោយមិនគិតគូដល់បញ្ហាសិទ្ធិមនុស្ស។ ក្នុងខែមករា ឆ្នាំ២០១៦ លោក ឃ្លាំង ហួត អភិបាលខណ្ឌជ្រោយចង្វា ដែលជាខណ្ឌរងផលប៉ះពាល់ធ្ងន់ធ្ងរដោយការសាងសង់ផ្លូវ បានប្រកាសជាថានេះជាគម្រោងសាធារណៈដោយប្រថុយប្រថាន និងបានថ្លែងការពារថាសាលារាជធានី *"នឹងមិនធ្វើការងារបម្រើដល់ផលប្រយោជន៍របស់បុគ្គលឬក្រុមហ៊ុនណាមួយឡើយ"* [33] ។ ប៉ុន្តែ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ គ្រឿងចក្ររបស់សាជីវកម្មវិនិយោគអាណិកជនកម្ពុជា Overseas Cambodia Investment Corporation ("OCIC") ត្រូវបានប្រើប្រាស់ដើម្បីឈូសឆាយដីធ្លីរបស់អ្នកភូមិបើកផ្លូវសម្រាប់ការស្ដាបនាផ្លូវ ដែលនេះបង្ហាញថាការអះអាងរបស់គ្រួសារពលរដ្ឋដែលរងផលប៉ះពាល់គឺត្រឹមត្រូវដែលថាគម្រោងនេះធ្វើឡើងដើម្បីផលប្រយោជន៍ក្រុមហ៊ុន OCIC ដែលកំពុងសាងសង់ទីក្រុងរណបលើផ្ទៃដីទំហំ ៣៨៧ ហិចតានៅជ្រោយចង្វានោះហើយដែលគម្រោងនេះបាននាំមានបន្លាស់ទីប្រជាពលរដ្ឋរាប់រយគ្រួសារ ជាជាងក្នុងបំណងជួយសម្រួលការកកស្ទះចរាចរណ៍[34]។ ពលរដ្ឋដែលរងផលប៉ះពាល់ក្នុងតំបន់នោះបានលើកឡើងថាសហគមន៍ដែលរស់នៅលើទីតាំងនោះ "មិនជំទាស់ទៅនឹងការស្ដាបនាផ្លូវនោះទេ" ប៉ុន្តែ ក្រុមហ៊ុននិងអាជ្ញាធរមូលដ្ឋានគួរផ្ដល់សំណងដល់ពួកគាត់ជាមុន"មិនមែនមកឈូសឆាយដូច្នេះឡើយ[35]"

---

31 គោលការណ៍ និងគោលការណ៍ណែនាំមូលដ្ឋានស្ដីពីការបណ្ដេញចេញ និងការបន្លាស់ទីដើម្បីការអភិវឌ្ឍរបស់ អ.ស.ប http://bit.ly/1SPR8VH

32 សែន ដេវីត "អ្នកភូមិបឹងត្របែកបដិសេធទទួលយកសំណង" សារព័ត៌មាន*ភ្នំពេញប៉ុស្ដិ៍* (ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥) http://bit.ly/1VA0Kdq

33 បែន សុខហាន "អ្នកភូមិតវ៉ាគម្រោងសាងសង់ផ្លូវនៅក្បែរទីតាំងអភិវឌ្ឍរបស់ក្រុមហ៊ុន OCIC " សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦) http://bit.ly/1rmgHr4

34 ពេជ្រ សុជាតិ និង Ananth Baliga "ការឈូសឆាយរបស់ក្រុមហ៊ុន OCIC នៅខណ្ឌជ្រោយចង្វារនៅតែបន្តទោះបីជាមានទំនាស់" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ (ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦) http://bit.ly/24pUHgS

35 ខួត សុភក្ត្រចរិយា (Khouth Sophak Chakrya) " ប្រជាពលរដ្ឋតវ៉ាការឈូសឆាយដីនៅតំបន់ជ្រោយចង្វារ សារព័ត៌មាន *ភ្នំពេញប៉ុស្ដិ៍* (ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦) http://bit.ly/1Tls4G9

។ រហូតមកដល់បច្ចុប្បន្ន ក្រុមហ៊ុននេះបានផ្តល់សំណងដល់អ្នកភូមិដែលបានរស់នៅលើដីនោះចាប់តាំងពីមុនឆ្នាំ១៩៩៣ ដោយព្រមផ្តល់ជូន ១៥ ដុល្លារសហរដ្ឋអាមេរិកក្នុងទំហំដីមួយម៉ែត្រក្រឡា។ មានការប៉ាន់ប្រមាណមួយចំនួនថាតាមទីផ្សារតម្លៃជិត២.០០០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយម៉ែត្រក្រឡា ហេតុដូច្នេះពលរដ្ឋជាច្រើនបានបដិសេធក្នុងការទទួលយកសំណងខាងលើ ហើយបានបន្តរស់នៅលើដីនោះ[36]។ បើទោះបីជាពលរដ្ឋជាច្រើនមិនទទួលសំណងសម្រាប់ដីរបស់ពួកគេក្តី សាលាក្រុងបានយល់ព្រមឱ្យក្រុមហ៊ុន OCIC បន្តគម្រោងទៅមុខទៀត ដោយប្រើគ្រឿងចក្រឈូសឆាយដីរបស់អ្នកភូមិនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ លោក សែន ណារិន មន្ត្រីសាលាខណ្ឌបាននិយាយថា "*យើងត្រូវតែធ្វើវាទោះបីជាពួកគេមិនទទួលសំណងក៏ដោយ ពីព្រោះយើងបានអញ្ជើញពួកគាត់ [ដើម្បីចរចា] ច្រើនលើកមកហើយ*[37]"។ ការថ្លែងរបស់លោក សែន ណារិន មិនបានផ្តល់ហេតុផលសមស្របឡើយ ហើយក្រុមហ៊ុន OCIC ខកខានក្នុងការគោរពតាមវិចារណកថារបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ស្តីពីការបណ្តេញចេញដើម្បីការអភិវឌ្ឍន៍នោះឡើយ។

ក្រុមហ៊ុន OCIC គ្រប់គ្រងដោយឧកញ៉ា ពុង ខៀវសែ បានទទួលសម្បទានដីសេដ្ឋកិច្ចរយៈពេល ៩៩ ឆ្នាំលើផ្ទៃដីទំហំ ៣៨៧ ហិចតា នៅជ្រោយតំបន់ចង្វាក្នុងចំនួនទឹកប្រាក់ដែលមិនត្រូវបានបង្ហាញក្នុងឆ្នាំ២០១១ តាមកិច្ចសន្យាអភិវឌ្ឍតំបន់ដែលលយតាមប្រសព្វទន្លេពីក្នុងរាជធានីភ្នំពេញនោះឱ្យក្លាយទៅជា "*ទីក្រុងនាពេលអនាគត*"[38]។ នៅដើមឆ្នាំ២០១៤ ក្រុមហ៊ុនបានចាប់ផ្តើមបូមខ្សាច់ចាក់បំពេញទន្លេសម្រាប់ការអភិវឌ្ឍ ដែលបង្កឱ្យបាក់ច្រាំង ហើយលំនៅដ្ឋានរបស់ប្រជាពលរដ្ឋជាច្រើននៅតាមមាត់ទន្លេរងការខូចខាតជាបន្តបន្ទាប់[39]។ ជាលទ្ធផលពួកគាត់បានជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លីដ៏អូសបន្លាយ ក្នុងអំឡុងពេលប្រជាពលរដ្ឋរងផលប៉ះពាល់ជាច្រើនគ្រួសារក្នុងសហគមន៍ទទួលសំណងយឺតយ៉ាវ និងដោយស្ទាក់ស្ទើរពីក្រុមហ៊ុនOCIC នោះ នៅថ្ងៃចុងក្រោយនៃការចាកចេញ លំនៅដ្ឋានរបស់ពួកគាត់ត្រូវបានកម្ទេចចោលនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ហើយទទួលបានសំណងត្រឹមតែ ៥០០ ដុល្លារសហរដ្ឋអាមេរិកសម្រាប់ការខូតខាតទាំងនោះ។ ក្រុមហ៊ុនបានចាប់ផ្តើមធ្វើការងារនៅលើដីធ្លីនោះ ដោយពុំបានធ្វើការប្រឹក្សាយោបល់ ឬផ្តល់ការប្រឹក្សាយោបល់ជាមុនឡើយ ដែលនេះជាការរំលោភបំពានទៅលើច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## សេចក្តីសន្និដ្ឋាន

ទន្ទឹមនឹងការបោះជំហានប្រកបដោយវិជ្ជមានមួយចំនួនរបស់រដ្ឋាភិបាលក្នុងការការពារសិទ្ធិមនុស្សទាក់ទិនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅរាជធានីភ្នំពេញ និងតាមរយៈការអន្តរាគមន៍របស់រដ្ឋាភិបាលនាពេលថ្មីៗនេះទៅ

---

[36] ពេជ្រ សុជាតិ និង Ananth Baliga "ការឈូសឆាយរបស់ក្រុមហ៊ុន OCIC នៅខណ្ឌជ្រោយចង្វារនៅតែបន្តទោះបីជាមានទំនាស់" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦) http://bit.ly/24pUHgS

[37] ប្រភពខាងលើ

[38] សេក ឧត្តម "សាលារាជធានីបែងចែកដីដែលអ្នកភូមិ និងក្រុមហ៊ុន OCIC អះអាងពីសិទ្ធិកាន់កាប់" ថ្ងៃអង្គារ៍ ទី ១០ ខែកុម្ភៈ ឆ្នាំ២០១៥ សារព័ត៌មាន *ខេមបូឌា ដេលី* http://bit.ly/1RoYMoQ

[39] ម៉ាត់ ប្លូមប៊ើក (Matt Blomberg) និងសេក ឧត្តម "ការបន្តបូមខ្សាច់ និងការបាត់បង់ដីនៅជ្រោយចង្វា" សារព័ត៌មាន *ខេមបូឌា ដេលី* (ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤) http://bit.ly/1TL3odc

លើគម្រោងអភិវឌ្ឍនានា សលាកប័ត្រព័ត៌មាននេះបង្ហាញពីផលប៉ះពាល់ធ្ងន់ធ្ងរ ដោយក្នុងករណីខ្លះបានផ្ទុយទៅនឹងច្បាប់ទាំងស្រុងដែលតម្រូវឱ្យមានការអន្តរាគមន៍ស្រដៀងគ្នានេះទៅលើគម្រោងអភិវឌ្ឍជាច្រើនផ្សេងទៀតក្នុងរាជធានីភ្នំពេញ។ គម្រោងទាំងនោះបង្ហាញនូវការខកខានរបស់រដ្ឋក្នុងការបំពេញនូវតួនាទីរបស់ខ្លួនក្នុងការការពារសិទ្ធិរបស់ពលរដ្ឋនៅពេលមានការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងវិស័យឯកជន។ ដូចមានចែងក្នុងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស[40] ទំនួលខុសត្រូវក្នុងការធានាឱ្យមានការកាពារនិងការគោរពសិទ្ធិមនុស្សនៅកម្ពុជា ជាកាតព្វកិច្ចរបស់រដ្ឋនិងអាជីវករ។ ស្ថិរភាពក្នុងការរស់នៅនិងលក្ខខណ្ឌការងារល្អប្រសើរ និងកាលដែលសិទ្ធិរបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានការពារគឺនឹងនាំមកនូវកំណើនសេដ្ឋកិច្ច ដូច្នេះហើយទាំងរដ្ឋនិងវិស័យឯកជនត្រូវធានាថាពួកគេនឹងចាត់វិធានការដ៏សមរម្យទាំងអស់ដើម្បីការពារ និងគោរពសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា។

ម.ស.ម.ក អំពាវនាវឱ្យរដ្ឋាភិបាលមេត្តាផ្អាកគម្រោងអភិវឌ្ឍដែលបង្កផលប៉ះពាល់ផ្សេងៗរហូតដល់មានការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គមត្រឹមត្រូវ ធ្វើការប្រឹក្សាយោបល់អោយបានគ្រប់ជ្រុងជ្រោយជាមួយពលរដ្ឋដែលរងផលប៉ះពាល់ ហើយត្រូវធានាថាសំណងដែលបានផ្តល់ទៅឱ្យគ្រួសារពលរដ្ឋដែលរងផលប៉ះពាល់ទាំងនោះគឺផ្អែកទៅលើតម្លៃទីផ្សារ។ ម្យ៉ាងទៀត រដ្ឋាភិបាលត្រូវធានាថាការបណ្តេញចេញដើម្បីការអភិវឌ្ឍត្រូវបានធ្វើឡើងតែក្នុងជម្រើសចុងក្រោយ និងឱ្យស្របទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក វណ្ណ សូផាត អ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ + ៨៥៥ (0) ១២ ៩៤ ១២ ០៦ ឬ អ៊ីម៉ែល ៖ vann.sophath@cchrcambodia.org ឬកញ្ញា អាលីហ្សា ខាំបៃយ៍ ទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរសព្ទ + ៨៥៥ (0) ១២ ៤៧ ៩១ ៧៤ ឬ អ៊ីម៉ែល ៖ alysha.khambay@cchrcambodia.org ។**

[40] អង្គការសហប្រជាជាតិ "គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស ៖ ការអនុវត្តតាមក្របខណ្ឌអង្គការសហប្រជាជាតិ "ការការពារ ការគោរព និងដំណោះស្រាយ" http://bit.ly/18WbEUy